ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ: ៣១ សជណ/សក/គគឈន/៦៨៧ រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

ក្នុងគោលបំណងការពារទ្រព្យសម្បត្តិសាធារណៈ ផ្លូវថ្នល់ ស្ពាន ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ផ្លូវថ្នល់ផ្សេងទៀតឱ្យមានចីរភាព ស្ថិតស្ថេរ គង់វង្ស និងជាប់រឹងមាំតាមអាយុកាលបច្ចេកទេសកំណត់ស្របតាមកម្រិតស្តង់ដានៃការសាងសង់ ក៏ដូចជាការចូលរួមចំណែកកាត់បន្ថយការចំណាយថវិកាជាតិក្នុងការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធទាំងនោះឡើងវិញដែលខូចមុនកាលកំណត់ និងដោយទទួលបានការឯកភាពពីរាជរដ្ឋាភិបាល **នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦** លើចំណាត់ការទប់ស្កាត់ និងបង្ក្រាបបទល្មើសដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ព្រមទាំងដើម្បីធានានូវប្រសិទ្ធភាពនិងមាននិរន្តរភាពក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

ក្រសួងសាធារណការនិងដឹកជញ្ជូនសូមជូនដំណឹងដល់**ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ម្ចាស់រថយន្តធុនធ្ងន់ ឬអ្នកបើកបររថយន្តធុនធ្ងន់ និងសាធារណជន**ឱ្យបានជ្រាបថា ក្រសួងនឹងរៀបចំក្រុមថ្លឹងចល័តដែលមានភារកិច្ចថ្លឹងយានយន្តដឹកជញ្ជូនទំនិញទាំងឡាយនៅតាមគោលដៅដូចជា មជ្ឈមណ្ឌលឃ្លាំងទំនិញ រោងចក្រផលិតសម្ភារៈធុនធ្ងន់ៗ កសិដ្ឋាននានានៅរដូវប្រមូលផល ការដ្ឋានផលិតថ្មដើម្បីត្រួតពិនិត្យថ្លឹងទម្ងន់ដឹកជញ្ជូនមុននឹងអាចធ្វើចរាចរណ៍នៅលើបណ្តាញផ្លូវថ្នល់ ឬនៅតាមផ្លូវវាងសំខាន់ៗដែលអ្នកបើកបររថយន្តដឹកជញ្ជូនលើសទម្ងន់បានបើកបរគេចវេសមិនចូលស្ថានីយថ្លឹងយានយន្ត។

ក្រសួងសូមរំលឹកដល់ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន **ម្ចាស់រថយន្តធុនធ្ងន់ ឬអ្នកបើកបររថយន្តធុនធ្ងន់ និងសាធារណជនទាំងអស់** សូមចូលរួមសហការអនុវត្តវិធានការខាងលើ និងរាយការណ៍មកក្រសួងអំពីករណីមន្ត្រីក្រោមឱវាទក្រសួងដែលបានចាត់ឱ្យទៅបម្រើការងារនៅតាមស្ថានីយថ្លឹងអចល័ត និងក្រុមថ្លឹងចល័តបានប្រព្រឹត្តមិនត្រឹមត្រូវតាមច្បាប់ទោះក្នុងរូបភាពណាក៏ដោយដូចជា ទារលុយ ឬដាក់ខែបង់លុយ ជាថ្នូរនឹងបណ្តែតបណ្តោយឱ្យប្រព្រឹត្តបទល្មើសដឹកជញ្ជូនលើសទម្ងន់ តាមរយៈហ្វេសប៊ុក (Facebook) www.facebook.com/mpwt.gov.kh ឬទូរស័ព្ទ Hot line 023 426 157 ។

ក្រសួងសាធារណការនិងដឹកជញ្ជូនសង្ឃឹមជឿជាក់ថា **ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូន ម្ចាស់រថយន្តធុនធ្ងន់ ឬអ្នកបើកបរ និងសាធារណជនទាំងអស់** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ តម្លាភាព សុចរិតភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយក្រសួងនឹងចាត់វិធានការអនុវត្តចំពោះរថយន្តដែលដឹកលើសទម្ងន់កម្រិតកំណត់ ចាប់ពី**ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦តទៅ**។

**ក្រសួងសាធារណការនិងដឹកជញ្ជូន**